## ១. បច្ចុប្បន្នភាពសមាគម

សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ជាសមាគមអព្យាក្រឹត មិនស្វែងរកប្រាក់កម្រៃជាឯកជនមិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើនយោបាយ មិនធ្វើជាឧបករណ៍របស់គណបក្សនយោបាយ ក្នុងនោះមិនផ្តល់ជាសម្ភារ ហិរញ្ញវត្ថុ ធនធានមនុស្ស ដើម្បីគាំទ្រគណបក្សនយោបាយ ឬបេក្ខជន ឬអ្នកគាំទ្រណាមួយឡើយ។ សមាគមបម្រើឱ្យផលប្រយោជន៍សមាជិក និងផលប្រយោជន៍សាធារណៈតាមលទ្ធភាពដែលសមាគមអាចចូលរួមបាន។

សមាគមបង្កើតឡើងនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១១ ដោយក្រុមអ្នកផ្គត់ផ្គង់ទឹកស្អាតឯកជនមួយក្រុមមានគ្នាប្រមាណជា ២០នាក់ ក្រោមជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ របស់គម្រោង អេម អេស អេម អ៊ី កម្ពុជា ( MSME) ឧបត្ថម្ភដោយទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) និងបានចុះបញ្ជីសមាគមជាផ្លូវការនៅក្រសួងមហាផ្ទៃ តាមសេចក្តីជូនដំណឹងលេខៈ ១០៧៧ សជណ របស់ក្រសួងមហាផ្ទៃ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០១២។ ក្រសួងមហាផ្ទៃចេញសេចក្តីប្រកាសលេខ: ២៩០១ ប្រក ចុះថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២១ សម្រេចចុះឈ្មោះសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ឡើងវិញក្នុងបញ្ជីសមាគមសម្រាប់នីតិបុគ្គលនៅក្រសួងមហាផ្ទៃ ដោយមានអាសយដ្ឋាននៃទីស្នាក់ការកណ្តាលស្ថិតនៅអគារ F ជាន់ទី២ បន្ទប់លេខ ២៦៩ នៃមជ្ឈមណ្ឌលភ្នំពេញ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

សមាគមបង្កើតឡើងក្នុងគោលបំណងប្រមូលផ្តុំអ្នករួមអាជីព ឬរួមវិជ្ជាជីវៈទាំងអស់ក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនប្រកាន់និន្នាការនយោបាយអ្វីឡើយ។

គិតត្រឹមត្រីមាសទី២ ឆ្នាំ២០២២ សមាគមមានសមាជិកសរុបចំនួន ៣១១ស្ថានីយ / ក្រុមហ៊ុន កំពុងប្រតិបត្តិការនៅក្នុង ២៣ខេត្ត/ក្រុង នៃព្រះរាជាណាចក្រកម្ពុជា ក្នុងនោះមានសមាជិកជាប្រតិបត្តិករផ្គត់ផ្គត់ទឹកស្អាតចំនួន ២៧៩ ស្ថានីយ និងសមាជិកជាក្រុមហ៊ុនផ្គត់ផ្គង់លើវិស័យទឹកស្អាតចំនួន ៣២ក្រុមហ៊ុន។

# ២. ក្រុមប្រឹក្សាភិបាល

## ២.១ ការចូលជួបសំដែងការគួរសម

នៅថ្ងៃពុធ ១២កើត ខែចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២២ ក្រុមប្រឹក្សាភិបាល និងបុគ្គលិកសមាគម បានចូលជួបសំដែងការគួរសម និងគោរពជូនពរដល់ ឯកឧត្តម **ភិតិសេដ្ឋា បណ្ឌិត ទេសរដ្ឋមន្ត្រី** រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងឯកឧត្តម **អ៊ុំ សុថា** រដ្ឋលេខាធិការ និងថ្នាក់ដឹកនាំព្រមទាំងមន្ត្រីទាំងអស់របស់ក្រសួងឧ.វ.ប.ន ក្នុងឱកាសចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ សូមមានសុខភាពល្អបរិបូរណ៍ ពលានុភាពខ្លាំងក្លា ប្រាជ្ញាវាងវៃ ជោគជ័យគ្រប់ភារកិច្ច និងសមប្រកបតែពុទ្ធពរទាំង៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។






*រូបភាពទី ១ និងទី២ ការចូលជួបសម្តែងការគួរសម និងថតរូបអនុស្សាវរីយ៍*

## ២.២ កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល

ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២២ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលសមាគមប្រចាំត្រីមាសទី២ ឆ្នាំ២០២២ ដើម្បីធ្វើបច្ចុប្បន្នភាពការងារគម្រោងដែលសមាគមបាននឹងកំពុងអនុវត្ត នឹងការជជែកពិភាក្សាអំពីការបង់ភាគទានរបស់សមាជិកផងដែរ។



*រូបភាពទី ៣ កិច្ចប្រជុំប្រចាំត្រីមាសរបស់ក្រុមប្រឹក្សាភិបាលនៅការិយាល័យសមាគម*

## ២.៣ កិច្ចប្រជុំជាមួយអគ្គនាយកដ្ឋានទឹកស្អាត

ថ្ងៃចន្ទ ៦រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២៖ កិច្ចប្រជុំរវាងអគ្គនាយកដ្ឋានទឹកស្អាត នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា នៅការិយាល័យអគ្គនាយកដ្ឋានទឹកស្អាត ដឹកនាំដោយ ឯកឧត្តម **តន់ សុខជា** ដោយមានការអញ្ជើញចូលរួមពីប្រធាននាយកដ្ឋាន និងមន្ត្រីនៃអគ្គនាយកដ្ឋាន និងភាគីខាងសមាគម (CWA) ដឹកនាំ លោក **ឡេង ខៀវ** ប្រធានក្រុមប្រឹក្សាភិបាល ដោយមានការអញ្ជើញចូមរួមពី ក្រុមប្រឹក្សាភិបាល និងថ្នាក់ដឹកនាំសមាគម។ កិច្ចប្រជុំបានពិភាក្សានឹងសម្រេច រៀបចំបន្ត អនុស្សារណៈនៃការយោគយល់គ្នាស្តីពី **«កិច្ចសហប្រតិបត្តិការលើវិស័យទឹកស្អាត»** រវាង អគ្គនាយកដ្ឋានទឹកស្អាត នៃក្រសួងឧ.វ.ប.ន និងសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា (CWA) សម្រាប់រយៈពេល ៥ឆ្នាំ គិតចាប់ពីខែវិច្ឆិកា ឆ្នាំ២០២២ តទៅ។



*រូបភាពទី ៤ ការជួបប្រជុំជាមួយ អគ្គនាយកនៃអគ្គនាយកដ្ឋានទឹកស្អាត*

## ២.៤ សិក្ខាសាលាពិគ្រោះយោបល់ និងប្រមូលធាតុចូលលើសេចក្តីព្រាងបឋមបទដ្ឋានគតិយុត្តចំនួន៤

ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ ក្រុមប្រឹក្សាភិបាល នាយកប្រតិបត្តិ និងសមាជិកសមាគម បានចូលរួម សិក្ខាសាលាពិគ្រោះយោបល់ និងប្រមូលធាតុចូលលើសេចក្តីព្រាងបឋមបទដ្ឋានគតិយុត្តចំនួន៤ ក្នុងក្របខណ្ឌគម្រោងកសាងសមត្ថភាពគ្រប់គ្រងវិស័យទឹកស្អាតកម្ពុជា ដែលរៀបចំដោយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍ និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) នៅទីស្តីការក្រសួង។



*រូបភាពទី ៥ សិក្ខាសាលាពិគ្រោះយោបល់ និងប្រមូលធាតុចូលលើសេចក្តីព្រាងបឋមបទដ្ឋានគតិយុត្តចំនួន៤*

## ៣. ការងារគម្រោង

### ៣.១ ការបង្កើននូវភាពធន់ នឹងការបម្រែបម្រួលអាកាសធាតុសម្រាប់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត (UNICEF)

នៅក្នុងត្រីមាសទី២នេះ ក្រុមការងារបច្ចេកទេសសមាគមបានចុះផ្ទៀងផ្ទាត់ការអនុវត្តន៍គម្រោងចំនួន ៤ លើកដូចខាងក្រោម៖

❖ ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២២ បុគ្គលិកបច្ចេកទេសសមាគម និងបុគ្គលិកអង្គការ UNICEF បានអនុវត្តសកម្មភាពមួយចំនួនដូចខាងក្រោម៖

1. ចុះផ្ទៀងផ្ទាត់ការពង្រីកបណ្តាញចែកចាយនៅស្ថានីយទឹកស្អាតក្រាំងចេក
2. ពិនិត្យការកែលម្អប្រភពទឹកនៅស្ថានីយទឹកស្អាត ប៉េង ហុង និង
3. ពិនិត្យការសាងសង់អនុស្ថានីយចែកចាយទឹកស្អាត នៅស្ថានីយទឹកស្អាត សេក គង់ ដែលស្ថិតនៅក្នុងស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ។



*រូបភាពទី ៦ ស្រះទឹកជីកថ្មីរបស់ស្ថានីយទឹកស្អាត សេក គង់ បាត់ដឹង*

❖ ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២២ បុគ្គលិកបច្ចេកទេសមាគម បានចុះទៅផ្ទៀងផ្ទាត់ការដំឡើងម៉ូទ័របូមទឹកពីអណ្តូងខួង នៅស្ថានីយផ្គត់ផ្គង់ទឹកស្អាតចំនួន ២គឺ

១). ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ប៉េងហុង

២). ស្ថានីយផ្គត់ផ្គង់ទឹកស្អាត សេក គង់ បាត់ដឹង



*រូបភាពទី ៧ ការតម្លើងម៉ូទ័រ ប៊ូមទឹកអណ្តូងនៅស្ថានីយ បាត់ដឹង និងស្ថានីយទឹកស្អាត ប៉េងហុង*

❖ ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២ បុគ្គលិកបច្ចេកទេសរបស់សមាគមបានចុះបង្វឹកដល់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតចំនួន ២គឺ ស្ថានីយផ្គត់ផ្គង់ទឹកស្អាត បូរីជលសារ និងស្ថានីយផ្គត់ផ្គង់ទឹកស្អាត ក្រាំងចេក ស្ដីពីបច្ចេកទេសក្នុងការផលិត និងផ្គត់ផ្គង់ទឹកស្អាត។



*រូបភាពទី ៨ ការពង្រឹងសមត្ថភាពដល់បុគ្គលិកស្ថានីយផ្គត់ផ្គង់ទឹកស្អាត ប៉េង ហុង*

❖ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ បុគ្គលិកបច្ចេកទេសរបស់សមាគមបានចុះបង្វឹកដល់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតចំនួន ៣គឺ ១). ស្ថានីយផ្គត់ផ្គង់ទឹកស្អាត វាលពង់ ២). ស្ថានីយផ្គត់ផ្គង់ទឹកស្អាត សេក គង់បាត់ដឹង និង ៣). ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ប៉េង ហុង ស្តីពីបច្ចេកទេសក្នុងការផលិត និងផ្គត់ផ្គង់ទឹកស្អាត។



*រូបភាពទី ៩ ការបង្វឹកស្តីពីបច្ចេកទេសក្នុងការផលិត និងផ្គត់ផ្គង់ទឹកស្អាត ដល់បុគ្គលិករបស់ស្ថានីយទឹកស្អាត*

## ៣.២ ការពង្រឹងគណនេយ្យភាពរបស់សេវាករផ្គត់ផ្គង់ទឹកស្អាត ដើម្បីលើកកម្ពស់សេវាកម្មទឹកស្អាត នៅក្នុងខេត្តកណ្តាល ខេត្តកំពង់ស្ពឺ និងខេត្តកំពង់ឆ្នាំង ) WaterAid )

### ៣.២.១. វគ្គបណ្តុះបណ្តាល

នៅក្នុងត្រីមាសទី២នេះ សមាគមបានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី«តួនាទី និងការទទួលខុសត្រូវលើសេវាកម្មផ្គត់ផ្គង់ទឹកស្អាត» និង «បច្ចេកទេសមូលដ្ឋាននៃការផលិតទឹកស្អាត និងការតេស្តគុណភាពទឹកស្អាត» ចំនួន ៣វគ្គ ជូនអាជ្ញាធរឃុំ/ស្រុក និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត នៅៈ

1. ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ដែលមានអ្នកចូលរួមសរុប ១៥នាក់ (ស្រី ៧នាក់)
2. ស្រុកអង្គស្នួល ខេត្តកណ្តាល ដែលមានអ្នកចូលរួមសរុប ២៧នាក់ (ស្រី ១២នាក់)
3. ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដែលមានអ្នកចូលរួមសរុប ១៨នាក់ (ស្រី ៥នាក់)



*រូបភាពទី ១០ រូបភាពវគ្គបណ្តុះបណ្តាលនៅស្រុកអង្គស្នួល*

### ៣.២.២. វគ្គបង្វឹក

នៅក្នុងត្រីមាសនេះផងដែរ សមាគមក៏បានសហការជាមួយរដ្ឋបាលស្រុកសំរោងទង ក្នុងការរៀបចំវគ្គបង្វឹកស្តីពី «**ការតេស្តគុណភាពទឹកស្អាត**» នៅឃុំទាំង ៦ របស់ស្រុកសំរោងទង ក្រោមការឧបត្ថម្ភពីអង្គការវ៉េតធីអេតកម្ពុជា។ អ្នកចូលរួមសរុបចំនួន ៥៣នាក់ (ស្រី ១៧នាក់) ដែលមានសមាសភាពចូលរួមពីតំណាងមន្ទីរឧ.រ.ប.ន ខេត្តកំពង់ស្ពឺ មន្ត្រីរដ្ឋបាលស្រុកសំរោងទង មេឃុំ សមាជិកក្រុមប្រឹក្សាឃុំ និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត។




*រូបភាពទី ១១ រូបភាពបង្វឹកអាជ្ញាធរនៅឃុំត្រពាំងគង*

### ៣.២.៣. កិច្ចប្រជុំថ្នាក់ឃុំ

នៅក្នុងត្រីមាសនេះផងដែរ សមាគមក៏បានសហការជាមួយរដ្ឋបាលស្រុកសំរោងទង ក្នុងការរៀបចំកិច្ចថ្នាក់ឃុំ នៅឃុំទាំង ៦ របស់ស្រុកសំរោងទង រួមមាន៖ ឃុំរលាំងគ្រើល ឃុំត្រពាំងគង ឃុំរលាំងចក ឃុំស្គុះ ឃុំក្រាំងអំពិល និងឃុំសែនដី។ អ្នកចូលរួមសរុបចំនួន ១៩៨នាក់ (ស្រី ៣៤នាក់) ដែលមានសមាសភាពចូលរួមពី តំណាងមន្ទីរឧ.វ.ប.ន ខេត្តកំពង់ស្ពឺ មន្ត្រីរដ្ឋបាលស្រុកសំរោងទង មេឃុំ សមាជិកក្រុមប្រឹក្សាឃុំ មេភូមិ ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត តំណាងមណ្ឌលសុខភាព តំណាងសាលារៀន និងតំណាងប៉ុស្តិ៍ប៉ូលីស។




*រូបភាពទី ១២ កិច្ចប្រជុំផ្សព្វផ្សាយគម្រោងជាមួយអាជ្ញាធរឃុំ*

### ៣.២.៤. កិច្ចប្រជុំឆ្លុះបញ្ចាំងការអនុវត្តគម្រោង

នៅក្នុងត្រីមាសទី២នេះ សមាគមបានរៀបចំកិច្ចកិច្ចប្រជុំពិគ្រោះយោបល់លើការអនុវត្តគម្រោងរវាង មន្ទីរពាក់ព័ន្ធ អង្គការតែជីអេតកម្ពុជា និងសមាគម បានចំនួន ៣ដង នៅ៖

1. ខេត្តកណ្តាល៖ មានអ្នកចូលរួមសរុប ៩នាក់ (ស្រី ៣នាក់)
2. ខេត្តកំពង់ឆ្នាំង៖ មានអ្នកចូលរួមសរុប ៨នាក់ (ស្រី ៤នាក់)
3. ខេត្តកំពង់ស្ពឺ៖ មានអ្នកចូលរួមសរុប ៣២នាក់ (ស្រី ៥នាក់)




*រូបភាពទី ១៣ ការប្រគល់សម្ភារៈធ្វើតេស្តសម្អាធទឹកដល់មន្ទីរ ឧវបន ខេត្តកណ្ដាល*

### ៣.២.៥. ការឧបត្ថម្ភធនលើតំណភ្ជាប់បណ្ដាញទឹកស្អាតជូនគ្រួសារក្រីក្រ

ត្រីមាសទី២នេះ សមាគមបានសម្របសម្រួលភ្ជាប់សេវាទឹកស្អាតជូនគ្រួសារក្រីក្របានចំនួន ១១៧ គ្រួសារ ដែលទទួលបានការឧបត្ថម្ភធនពី ១).ក្រុមហ៊ុនលង្វែក ឌីវេឡុបម៉ិន រ៉ែតធើរ សឹបផ្លាយ ឯ.ក និង ២).ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ក្តុល និងគម្រោងដែលគាំទ្រថវិកាដោយអង្គការវ៉ែតធឺអេតកម្ពុជា។ ជាលទ្ធផល ៧៤គ្រួសារបានផ្ទៀងផ្ទាត់រួច ៤៣គ្រួសារមិនទាន់បានផ្ទៀងផ្ទាត់(ក្រុមការងារនឹងផ្ទៀងផ្ទាត់នៅត្រីមាសក្រោយ)។



*រូបភាពទី ១៤ រូបភាពគ្រួសារក្រីក្រនៅឃុំស្វាយ ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង*

### ៣.២.៦ ទស្សកិច្ចសិក្សារបស់ម្ចាស់ជំនួយ WaterAid

នៅថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២២ សមាគមបានសម្របសម្រួលដំណើរទស្សនកិច្ចសិក្សាស្វែងយល់អំពីប្រព័ន្ធសម្អាតទឹក នៅក្រុមហ៊ុនលង្វែក ឌីវេឡុបមិន វ៉តធើរ ស៊ីបផ្លាយ ឯ.ក តាមរយៈគម្រោងការពង្រឹងគណនេយ្យភាពរបស់សេវាករផ្គត់ផ្គង់ទឹកស្អាតដម្បីលើកកម្ពស់សេវាកម្មទឹកស្អាតដែលទទួលបានការឧបត្ថម្ភគាំទ្រពី អង្គការ វ៉តធឺអេតកម្ពុជា។



*រូបភាពទី ១៥ រូបភាពទស្សកិច្ចសិក្សារបស់ម្ចាស់ជំនួយ WaterAid*

## ៣.៣ បង្កើន**ការទទួលសេវាទឹកស្អាត និងអនាម័យដែលធន់នឹងអាកាសធាតុសម្រាប់ជនងាយរងគ្រោះនៅតាមសហគមន៍ និងភាពជាអ្នកដឹកនាំរបស់ស្ត្រីធ្វើមក្នុងវិស័យទឹកស្អាត និងអនាម័យប្រកបដោយបរិយាបន្ន** ( WaterAid )

### ៣.៣.១ សិក្ខាសាលាផ្សព្វផ្សាយគម្រោង

នៅដើមត្រីមាសទី២នេះ សមាគមបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយគម្រោង «បង្កើនការទទួលសេវាទឹកស្អាត និងអនាម័យដែលធន់នឹងអាកាសធាតុសម្រាប់ជនងាយរងគ្រោះនៅតាមសហគមន៍ និងភាពជាអ្នកដឹកនាំរបស់ស្ត្រីធ្វើមក្នុងវិស័យទឹកស្អាត និងអនាម័យប្រកបដោយបរិយាបន្ន» ចំនួន ២ប្រជុំ។ សមាសភាពអ្នកចូលរួមអញ្ជើញមកពី តំណាងមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ តំណាងមន្ទីរអភិវឌ្ឍន៍ជនបទ តំណាងរដ្ឋបាលស្រុក ក្រុមប្រឹក្សាឃុំ តំណាងសមាគមជនពិការ ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត បុគ្គលិកអង្គការវ៉តធឺអេតកម្ពុជា និងបុគ្គលិកសមាគម។

1. នៅសាលប្រជុំសាលាស្រុកល្វាឯម មានអ្នកចូលរួមចំនួន ២២នាក់
2. នៅសាលប្រជុំសាលាស្រុកស្អាង មានអ្នកចូលរួមចំនួន ១៨នាក់។



*រូបភាពទី ១៦ រូបភាពសិក្ខាសាលាផ្សព្វផ្សាយគម្រោងនៅក្នុងសាលប្រជុំសាលាស្រុកល្វាឯម*

## ៣.៣.២ វគ្គបង្វឹក

សមាគមបានរៀបចំវគ្គបង្វឹកស្តីពី «**ការតេស្តគុណភាពទឹកស្អាត**» និង«**សេវាកម្មអតិថិជន**» ទៅដល់បុគ្គលិករបស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ដោយមានការជួបជុំផ្ទាល់នៅស្ថានីយផ្គត់ផ្គង់ទឹកស្អាតចំនួន ៤ទីតាំង ១.ស្ថានីយផ្គត់ផ្គង់ទឹកស្អាតកោះខ្សាច់ទន្លា ២.ស្ថានីយទឹកស្អាត ឡេង ខៀវព្រែកអំបិល ៣.ស្ថានីយផ្គត់ផ្គង់ទឹកស្អាតស្វាយប្រទាល និង៤.ស្ថានីយផ្គត់ផ្គង់ទឹកស្អាតទីប្រជុំជនត្រើយស្លា នៅក្នុងស្រុកស្អាង និងចំនួន ១ទីតាំង នៅស្ថានីយផ្គត់ផ្គង់ទឹកស្អាត ព្រែកឫស្សី ក្នុងស្រុកល្វាឯម។



*រូបភាពទី ១៧ ការធ្វើជាតេស្ត (Jar Test) របស់បុគ្គលិកសមាគម នៅទឹកស្អាត ស្វាយប្រទាល ស្រុកស្អាង*

### ៣.៣.៣ ទិន្នន័យគ្រួសារក្រីក្រ

សមាគមបានសហការជាមួយសមាគមជនពិការស្រុកស្អាង ដើម្បីប្រមូលទិន្នន័យដើមគ្រាអំពីគ្រួសារក្រីក្រដែលបានភ្ជាប់ទឹកស្អាតរួច និងមិនទាន់បានភ្ជាប់ នៅក្នុងឃុំចំនួន ៥ គឺ ១). ឃុំស្វាយប្រទាល ២). ឃុំព្រែកអំបិល ៣). ឃុំកោះខែល ៤). ឃុំកោះខ្សាច់ទន្លា និង ៥). ឃុំត្រើយស្លា ស្រុកស្អាង ខេត្តកណ្ដាល ដែលជាតំបន់សេវាកម្មរបស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាត (១). ស្ថានីយផ្គត់ផ្គង់ទឹកស្អាតកោះខ្សាច់ទន្លា ២). ស្ថានីយទឹកស្អាត ឡេង ខៀវ ព្រែកអំបិល ៣). ស្ថានីយផ្គត់ផ្គង់ទឹកស្អាតស្វាយប្រទាល និង ៤). ស្ថានីយផ្គត់ផ្គង់ទឹកស្អាតទីប្រជុំជនត្រើយស្លា)។



*រូបភាពទី ១៨ រូបភាពបុគ្គលិកសមាគមចុះប្រមូលទិន្នន័យគ្រួសារក្រីក្រ*

## ៣.៤ ការពង្រឹងមូលដ្ឋានគ្រឹះសម្រាប់សន្តិសុខទឹកនៅកម្រិតស្រុកក្នុងប្រទេសកម្ពុជា (WaterAid)

### ៣.៤.១ ការរៀបចំវគ្គបណ្ដុះបណ្ដាល

ក្នុងត្រីមាសនេះ សមាគមបានផ្ដល់វគ្គបណ្ដុះបណ្ដាលចំនួនគឺ

- **បច្ចេកទេសនៃការផលិតទឹកស្អាត និងការតេស្តគុណភាពទឹកស្អាត** ជូនដល់អាជ្ញាធរមូលដ្ឋាន និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត ចំនួន ១៨នាក់ (ស្រី ៥នាក់) នៅក្នុងស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង។
- **វិធានការកាត់បន្ថយផលប៉ះពាល់ពីគ្រោះរាំងស្ងួត និងទឹកជំនន់សម្រាប់ការផ្ដល់សេវាផ្គត់ផ្គង់ទឹកស្អាត** ជូនដល់អាជ្ញាធរមូលដ្ឋាន និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតចំនួន២១នាក់ ស្រី៥នាក់ នៅក្នុងស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង។




*រូបភាពទី ១៩ រូបភាពប្រជុំបើកវគ្គបណ្តុះបណ្តាល នៅសាលាស្រុកសាមគ្គីមានជ័យ*

## ៣.៥ គម្រោងឧបត្ថម្ភធនលើថ្លៃភ្ជាប់ទឹកជូនគ្រួសារក្រីក្រ (EMW)

### ៣.៥.១ ការចុះផ្ទៀងផ្ទាត់ទិន្នន័យ

ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២២ ក្រោមការឧបត្ថម្ភពីអង្គការមូលនិធិ លោកខាងលិចជួបខាងកើត (EMW) តាមរយៈគម្រោងឧបត្ថម្ភធនលើថ្លៃភ្ជាប់ទឹកសម្រាប់គ្រួសារក្រីក្រ សមាគមបានចុះផ្ទៀងផ្ទាត់តំណគ្រួសារក្រីក្រ នៅស្ថានីយទឹកស្អាត ផារ័ត្ន វឌ្ឍនៈ និងកិច្ចប្រជុំជាមួយក្រុមប្រឹក្សាឃុំស្ពឹងជ័យ មេភូមិ ដើម្បីពន្លឿការតភ្ជាប់ទឹកស្អាតជូនប្រជាពលរដ្ឋ។



*រូបភាពទី ២០ កិច្ចប្រជុំរវាង ម្ចាស់ស្ថានីយ អាជ្ញាធរភូមិ និងម្ចាស់ជំនួយ មុនចុះផ្ទៀងផ្ទាត់ទិន្នន័យ*

### ៣.៥.២ កិច្ចប្រជុំការតភ្ជាប់បណ្តាញគ្រួសារក្រីក្រ

ថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២២ សមាគមបានរៀបចំកិច្ចប្រជុំពន្លឿនការតភ្ជាប់បណ្តាញគ្រួសារក្រីក្ររបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត ដែលទទួលបានការគាំទ្រពីអង្គការ លោកខាងលិចជួបខាងកើត (EMW)។ កិច្ចប្រជុំមានអ្នកចូលរួមចំនួន ១៣នាក់ មកពី ៨ស្ថានីយ។



*រូបភាពទី ២១ កិច្ចប្រជុំពន្លឿនការតភ្ជាប់បណ្តាញគ្រួសារក្រីក្រនៅការិយាល័យសមាគម*

## ៣.៦ គម្រោងសម្ព័ន្ធភាពដើម្បីអភិវឌ្ឍប្រកបដោយចីរភាព និងការគាំទ្រសំឡេងដើម្បីសមធម៌ (Aide et Action)

### ៣.៦.១ សិក្ខាសាលាផ្សព្វផ្សាយគម្រោង

នៅក្នុងត្រីមាសទី២ សមាគមបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ អំពីគម្រោង ជូនដល់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត និងអាជ្ញាធរភូមិឃុំ ចំនួន ២លើកដូចខាងក្រោម៖

- ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២ សិក្ខាសាលាផ្សព្វផ្សាយ «គម្រោងសម្ពន្ធភាពដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព និងការគាំទ្រសំឡេងដើម្បីសមធម៌សង្គម» នៅស្រុកដំណាក់ចង្អើរ ខេត្តកែប ដែលមានអ្នកចូលរួមសរុបចំនួន ១៣នាក់ រួមមាន៖ អភិបាលរងស្រុកដំណាក់ចង្អើរ ប្រធានរដ្ឋបាលស្រុក ក្រុមប្រឹក្សាឃុំអង្កោល និងឃុំពងទឹក អនុប្រធានការិយាល័យ ផែនការគាំទ្រឃុំ ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតស្រុកដំណាក់ចង្អើរ តំណាងសហគមន៍នេសាទ តំណាងអង្គការ Aide et Action និងបុគ្គលិកសមាគម។



*រូបភាពទី ២២ សិក្ខាសាលាផ្សព្វផ្សាយនៅស្រុកដំណាក់ចង្អើរ ខេត្តកែប*

❖ ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២២ សិក្ខាសាលាផ្សព្វផ្សាយ «គម្រោងសម្ពន្ធភាពដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព និងការគាំទ្រសំឡេងដើម្បីសមធម៌សង្គម» នៅស្រុកកំពង់ត្រាច ខេត្តកំពត ដែលមានអ្នកចូលរួមសរុបចំនួន ១៥នាក់ រួមមាន៖ អភិបាលរងស្រុក នាយរដ្ឋបាលស្រុក ការិយាល័យអប់រំ យុវជន និងកីឡា តំណាងសហគមន៍នេសាទ ប្រធានការិយាល័យគាំទ្រឃុំសង្កាត់ ក្រុមប្រឹក្សាឃុំគោលដៅទាំងប្រាំ ( ១. ឃុំព្រៃកក្រើស ២. ឃុំឫស្សីស្រុកខាងកើត ៣. ឃុំឫស្សីស្រុកខាងលិច ៤.ឃុំស្វាយទទឹងខាងជើង និង៥. ៤.ឃុំស្វាយទទឹងខាងត្បូង ) ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតស្រុកកំពង់ត្រាច តំណាងអង្គការ Aide et Action និងបុគ្គលិកសមាគម។



*រូបភាពទី ២៣ សិក្ខាសាលាផ្សព្វផ្សាយ នៅស្រុកកំពង់ត្រាច ខេត្តកំពត*

### ៣.៦.២ ការចុះប្រមូលទិន្នន័យ

ថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២២ ក្រុមការងារបច្ចេកទេសសមាគមបានចុះប្រមូលព័ត៌មានពីប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត នៅក្នុងខេត្តគោលដៅរបស់គម្រោងរួមមាន៖ ខេត្តកោះកុង ព្រះសីហនុ និងកំពត។

គោលបំណងនៃការចុះប្រមូលព័ត៌មានគឺដើម្បីស្វែងយល់ពីសមត្ថភាព និងលទ្ធភាពរបស់ប្រតិបត្តិករក្នុងការពង្រីកបណ្តាញរបស់ខ្លួនទៅកាន់ភូមិដែលមិនទាន់មានទឹកស្អាតប្រើប្រាស់ ដំណើរការនៃការផលិតទឹកស្អាត គុណភាពទឹក និងផែនការអាជីវកម្ម ។

## ៣.៧ គម្រោងរៀបចំព័ត៌មានប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតសម្រាប់រកទុនកម្ចី Water.org

ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២២ ក្រោមជំនួយឧបត្ថម្ភពីអង្គការ Water.org សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា សហការជាមួយក្រុមហ៊ុន អ៊ី.វ៉ោវ័រ ស៊ី ស៊ី អិល ឯ.ក បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយអំពី«**ប្រព័ន្ធគ្រប់គ្រងទិន្នន័យអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត**» ក្រោមអធិបតីភាព ឯកឧត្តម **រស់ សាលី** អនុរដ្ឋលេខាធិការក្រសួង ឧ.វ.ប.ន។ វគ្គសិក្ខាសាលានេះមានអ្នកចូលរួមសរុប ៥៥នាក់ (ស្រី២០នាក់) អញ្ជើញមកពី ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ តំណាងអង្គការ Water.org តំណាងក្រុមហ៊ុន E-Water បុគ្គលិកសមាគម និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត ចំនួន ៣៦ស្ថានីយ ។



*រូបភាពទី ២៤ ការធ្វើបទបង្ហាញអំពីគម្រោងជូនដល់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត នៅសណ្ឋាគារសាន់វេ ភ្នំពេញ*



*រូបភាពទី ២៥  ការថតរូបអនុស្សាវរីយ៍ក្រោយបញ្ចប់សិក្ខាសាលា*

## ៤. ការសម្របសម្រួលសមាជិក

### ៤.១. ការដោះស្រាយវិវាទ

ថ្ងៃសុក្រ ៧កើត ខែចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី៨ ខែមេសា ឆ្នាំ២០២២ សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ដឹកនាំដោយ លោក **ឡេង ខៀវ** ប្រធានក្រុមប្រឹក្សាភិបាល បានជួបប្រជុំជាមួយក្រុមហ៊ុនកាស៊ីណូគ្រោន ដែលដឹកនាំដោយ លោក **សេខ ស៊ីណា** អគ្គនាយកក្រុមហ៊ុន និង លោក **ចាម ប្រុស** តំណាងម្ចាស់ស្ថានីយទឹកស្អាត ចាន់ ណារី បានជួបប្រជុំនៅការិយាល័យក្រុមហ៊ុនកាស៊ីណូគ្រោន នៅភូមិជ្រៃធំ

ឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្តាល ដើម្បីដោះស្រាយបញ្ហា«**ការផ្គត់ផ្គង់ទឹកស្អាតរបស់ក្រុមហ៊ុនកាស៊ីណូក្រោន នៅក្នុងតំបន់អាជ្ញាប័ណ្ណទឹកស្អាត ចាន់ ណារី**» ដែលជាសមាជិករបស់សមាគម។ ភាគីទាំងពីរបានឯកភាពយកសំណើរបស់ភាគីទាំងសងខាងទៅសុំយោបល់ម្ចាស់ក្រុមហ៊ុនរៀងៗខ្លួន។ កិច្ចប្រជុំបញ្ចប់ដោយភាពយោគយល់និងស្និទ្ធស្នាល។



*រូបភាពទី ២៦ កិច្ចដោះស្រាយវិវាទរវាង ស្ថានីយទឹកស្អាត ចាន់ ណារី និងក្រុមហ៊ុនកាស៊ីណូក្រោន*

## ៤.២. ការតេស្ត និងវិភាគគុណទឹកជូនប្រតិបត្តិករ

ការធ្វើតេស្ត និងវិភាគគុណភាពទឹកឆៅ របស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាត គ្រាង ស្រីពេជ្រ ដើម្បីកំណត់បរិមាណសារធាតុគីមីសម្រាប់យកមកលាយដើម្បីផលិតទឹកស្អាតឱ្យមានគុណភាពល្អស្របតាមស្តង់ដាទឹកស្អាតថ្នាក់ជាតិ។



*រូបភាពទី ២៧ ការធ្វើតេស្ត និងវិភាគគុណភាពទឹកឆៅ របស់វិស្វករទឹកស្អាតសមាគម (CWA)*

## ៥. ការចុះអនុស្សារណៈនៃការយោគយល់

នៅក្នុងត្រីមាសទី២ សមាគមបានចុះអនុស្សារណៈនៃការយោគយល់គ្នាចំនួន ២គឺ៖

❖ ថ្ងៃទី៧ ខែមេសា ឆ្នាំ២០២២ ពិធីចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់គ្នារវាង **ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា ម.ក** និង **សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា** (CWA) ដោយ លោក **ឡេង ខៀវ** ប្រធានក្រុមប្រឹក្សាភិបាលនៃសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា និង លោក **លឹម អូន** អគ្គនាយកនៃធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា។ តាមអនុស្សារណៈនៃការយោគយល់គ្នានេះ ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា ម.ក នឹងផ្តល់អតិភាពជូនដល់សមាជិករបស់សមាគមក្នុងការទទួលបានកម្ចី សម្រាប់ការពង្រីកអាជីវកម្មរបស់ខ្លួន ជាពិសេសប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត។




*រូបភាពទី ២៨ ការចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នារវាង SME Bank & CWA*

❖ ថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២២ ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នារវាង **សមាគមទឹកអូស្ត្រាលី** (AWA) និង **សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា** (CWA) នៅទីក្រុង Brisbane, Australia សម្រាប់រយៈពេល ២ឆ្នាំបន្ត ដើម្បីបង្កើនកិច្ចសហការល្អ រវាងសមាគមទាំងពីរ។




*រូបភាពទី ២៩ ការចុះអនុស្សរណៈយោគយល់គ្នារវាង សមាគមទឹកអូស្ត្រាលី និងសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា*

## ៦. កិច្ចសហប្រតិបត្តិអន្តរជាតិ

- ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២២ សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា (CWA) បានសហការជាមួយ សមាគមទឹកអូស្ត្រាលី (AWA) កម្មវិធីវិនិយោគលើវិស័យហេដ្ឋារចនាសម្ព័ន្ធ (3i) និងក្រុមហ៊ុនផ្គត់ផ្គង់ទឹកស្អាត វី វេនឈ័រ រៀបចំសិក្ខាសាលាស្តីពី «ការចែករំលែកចំណេះដឹងពីបច្ចេកវិទ្យា Ultra-Filtration និងលទ្ធផលនៃការសាកល្បងប្រើប្រាស់បច្ចេកវិទ្យសម្អាតទឹក Ultra-Filtration»។



*រូបភាពទី ២៩ ការចូលរួមវគ្គសិក្ខាសាលានៅការិយាល័យសមាគម*

- ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២២ ក្រោមកិច្ចសហការរវាងសមាគមទឹកអូស្ត្រាលី កម្មវិធីវិនិយោគលើវិស័យហេដ្ឋារចនាសម្ព័ន្ធ (3i) និងសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា បានរៀបចំវេទិកាពិភាក្សាស្តីពី គោលនយោបាយទឹក កម្ពុជា អូស្ត្រាលី លើកទី២




*រូបភាពទី ៣០ វេទិកាពិភាក្សាស្តីពី គោលនយោបាយទឹក កម្ពុជា អូស្ត្រាលី លើកទី២*

❖ ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២២ សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា បានរៀបចំដំណើរទស្សនកិច្ច ជូនគណៈប្រតិភូអូស្ត្រាលី (សមាគមទឹកអូស្ត្រាលី និងមន្ត្រីទូតរបស់អូស្ត្រាលី) ទៅទស្សនកិច្ចសិក្សានៅស្ថានីយទឹកស្អាតទឹកស្អាតចំនួន៣ រួមមានៈ ស្ថានីយផ្គត់ផ្គង់ទឹកស្អាត កំពង់ចំលង ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ទ្បេង ខៀវ ព្រៃកអំបិល និងស្ថានីយផ្គត់ផ្គង់ទឹកស្អាត បែកចាន។



*រូបភាពទី ៣១ រូបថតអនុស្សាវរីយ៍នៅស្ថានីយផ្គត់ផ្គង់ទឹកស្អាត កំពង់ចំលង*



*រូបភាពទី ៣២ រូបថតអនុស្សាវរីយ៍នៅស្ថានីយផ្គត់ផ្គង់ទឹកស្អាត ទ្បេង ខៀវ ព្រៃកអំបិល*